**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៤៧. សសរ

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតគណៈបញ្ជាការដឹកនាំត្រួតពិនិត្យ និងលុបបំបាត់ការដាក់ប៉ុស្តិ៍ត្រួតពិនិត្យអនាធិបតេយ្យតាមផ្លូវគោក-ផ្លូវទឹក

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការពារជាតិ

-បានឃើញអនុក្រឹត្យលេខ ០២២/អនក្រ ចុះថ្ងៃទី៩ ខែឧសភា ឆ្នាំ១៩៩៤ ស្តីពីការបង្កើតគណៈបញ្ជាការ ឯកភាពខេត្ត-ក្រុង

-យោងអនុសាសន៍ដឹកនាំដ៏ខ្ពង់ខ្ពស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

-យោងតាមការចាំបាច់

## <u>សម្រេច</u>

<u>-ប្រការ១៖</u> ត្រូវបានបង្កើតគណៈបញ្ជាការដឹកនាំត្រួតពិនិត្យ និងលុបបំបាត់ការដាក់ប៉ុស្តិ៍ត្រួតពិនិត្យអនាធិបតេយ្យតាមផ្លូវគោក-ផ្លូវទឹក ដែលមានសមាសភាព ដូចតទៅ:

១-ឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ប្រធាន

២-ឯកឧត្តមនាយឧត្តមសេនីយ៍ ទៀ បាញ់ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ អនុប្រធាន

៣-ឯកឧត្តមនាយឧត្តមសេនីយ៍ ប៉ុល សារឿន អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ សមាជិក

៤-ឯកឧត្តមនាយឧត្តមសេនីយ៍ នេត សាវឿន អគ្គស្នងការនគរបាលជាតិ សមាជិក

៥-ឯកឧត្តមនាយឧត្តមសេនីយ៍ កេត សុភា អគ្គមេបញ្ជាការរង មេបញ្ជាការកងទ័ព

៦-ឯកឧត្តមនាយឧត្តមសេនីយ៍ សៅ សុខា អគ្គមេបញ្ជាការរង មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស សមាជិក
៧-ឯកឧត្តម ឧត្តមសេនីយ៍ឯក ទៀ វិញ មេបញ្ជាការកងទ័ពជើងទឹក សមាជិក
៨-ប្រធានគណៈបញ្ជាការឯកភាពរាជធានី-ខេត្ត សមាជិក
៩-មេបញ្ជាការយោធភូមិភាគទាំង ៦ សមាជិក

<u>ប្រការ២៖</u> -គណៈបញ្ជាការដឹកនាំត្រួតពិនិត្យ និងលុបបំបាត់ការដាក់ប៉ុស្តិ៍ត្រួតពិនិត្យអនាធិបតេយ្យតាមផ្លូវគោក-ផ្លូវទឹក មានភារកិច្ចទទួលខុសត្រូវដូចខាងក្រោម ៖

-ដាក់ចេញគោលការណ៍ណែនាំ និងវិធានការផ្សេងៗ ដើម្បីលុបបំបាត់ការដាក់ប៉ុស្តិ៍ត្រួតពិនិត្យអនាធិបតេយ្យតាមផ្លូវគោក និងផ្លូវទឹក ។

-រៀបចំឲ្យមានកិច្ចសហការគ្នារវាងរដ្ឋបាលរាជធានី-ខេត្ត កងកម្លាំងនគរបាល កងរាជអាវុធហត្ថ និងកងយោធពលខេមរភូមិន្ទ ចាត់តាំងល្បាត-ត្រួតពិនិត្យការដាក់ប៉ុស្តិ៍ត្រួតពិនិត្យអនាធិបតេយ្យតាមផ្លូវគោក-ផ្លូវទឹកជាប្រចាំ ដើម្បីបង្ក្រាបលុបបំបាត់ភ្លាមៗ និងដោះស្រាយពេលមានសេចក្តីរាយការណ៍ពីប្រជាពលរដ្ឋ ។

-ជំរុញការបំផុសចលនាប្រជាពលរដ្ឋឲ្យចូលរួមក្នុងការលុបបំបាត់ ប៉ុស្តិ៍ត្រួតពិនិត្យអនាធិបតេយ្យដោយត្រូវលើកទឹកចិត្តឲ្យមានសេចក្តីរាយការណ៍ ជូនដំណឹងដល់សមត្ថកិច្ចទាន់ពេលវេលាពេលឃើញមានសកម្មភាពដាក់ប៉ុស្តិ៍ត្រួតពិនិត្យខុសច្បាប់ ។

-អប់រំមន្ត្រីជំនាញគ្រប់ផ្នែក ដែលចុះបំពេញបេសកកម្មតាមមូលដ្ឋានត្រូវអនុវត្តឲ្យបានត្រឹមត្រូវតាមតួនាទី-ភារកិច្ចដែលប្រគល់ជូន ហាមដាច់ខាតការឆ្លៀតឱកាសដើម្បីប្រព្រឹត្តបទល្មើស ។

-ប្រមូលផ្តុំព័ត៌មាន ឬពាក្យបណ្តឹងទាក់ទងដល់ការដាក់ប៉ុស្តិ៍ត្រួតពិនិត្យអនាធិបតេយ្យ ដើម្បីពិនិត្យដោះស្រាយ និងលុបបំបាត់ឲ្យបានទាន់ពេលវេលា ។

-រៀងរាល់ខែគណៈបញ្ជាការ ត្រូវធ្វើរបាយការណ៍បូកសរុបលទ្ធផលការងារលុបបំបាត់ប៉ុស្តិ៍ត្រួតពិនិត្យអនាធិបតេយ្យតាមផ្លូវគោក និងផ្លូវទឹក ជូនមករាជរដ្ឋាភិបាល ។

<u>ប្រការ៣៖</u> ត្រូវបានបង្កើតលេខាធិការដ្ឋានគណៈបញ្ជាការដឹកនាំត្រួតពិនិត្យ និងលុបបំបាត់ការដាក់ប៉ុស្តិ៍ត្រួតពិនិត្យអនាធិបតេយ្យតាមផ្លូវគោក និងផ្លូវទឹក ដែលមានសមាសភាព ដូចតទៅ៖

១-ឯកឧត្តម នាយឧត្តមសេនីយ៍ នេត សាវឿន អគ្គស្នងការនគរបាលជាតិ ប្រធាន
២-ឯកឧត្តម នាយឧត្តមសេនីយ៍ មាស សុភា អគ្គមេបញ្ជាការរង មេបញ្ជាការកងទ័ពជើងគោក អនុប្រធាន
៣-ឯកឧត្តម នាយឧត្តមសេនីយ៍ សៅ សុខា អគ្គមេបញ្ជាការរង មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស អនុប្រធាន
៤-ឯកឧត្តម ឧត្តមសេនីយ៍ឯក កង សុខន អគ្គស្នងការរងនគរបាលជាតិ សមាជិក
៥-ឯកឧត្តម ឧត្តមសេនីយ៍ឯក យុន ឈុន្នី អគ្គស្នងការរងនគរបាលជាតិ សមាជិក
៦-ឯកឧត្តម ឧត្តមសេនីយ៍ឯក ដាំ វុទ្ធី អគ្គស្នងការរងនគរបាលជាតិ សមាជិក
៧-ឯកឧត្តម ឧត្តមសេនីយ៍ឯក រស់ ពិសេន មេបញ្ជាការរងកងរាជអាវុធហត្ថលើផ្ទៃប្រទេស សមាជិក
៨-ឯកឧត្តម ឧត្តមសេនីយ៍ឯក អ៊ុក សីហា មេបញ្ជាការរង កងទ័ពជើងទឹក សមាជិក
៩-ឯកឧត្តម ឧត្តមសេនីយ៍ឯក គៀត ច័ន្ទថារិទ្ធ ប្រធានសេនាធិការអគ្គស្នងការដ្ឋាននគរបាលជាតិ សមាជិក

**ប្រការ៤ ៖** លេខាធិការដ្ឋាន មានភារកិច្ចទទួលខុសត្រូវដូចខាងក្រោម ៖

-ជួយប្រធានគណៈបញ្ជាការក្នុងការផ្សព្វផ្សាយ តាមដាន និងចាត់ការអនុវត្តគោលការណ៍ណែនាំការផ្សេងៗ ដើម្បីលុបបំបាត់ការដាក់ប៉ុស្តិ៍ត្រួតពិនិត្យអនាធិបតេយ្យតាមផ្លូវគោក និងផ្លូវទឹក ។

-ផ្សព្វផ្សាយបទបញ្ជា-ផែនការ និងការណែនាំផ្សេងៗរបស់គណៈបញ្ជាការទៅស្ថាប័ន ឬអង្គភាពពាក់ព័ន្ធ និងអង្គភាពចំណុះ ទាក់ទិននឹងការលុបបំបាត់ការដាក់ប៉ុស្តិ៍ត្រួតពិនិត្យអនាធិបតេយ្យ ។

-តាមដានត្រួតពិនិត្យ ការចាត់តាំងកម្លាំងប្រតិបត្តិការ និងការផ្តួចផ្តើមគោលការណ៍ណែនាំការណ៍នានា ដើម្បីធ្វើឲ្យកាន់តែមានប្រសិទ្ធភាពក្នុងការលុបបំបាត់ការដាក់ប៉ុស្តិ៍ត្រួតពិនិត្យអនាធិបតេយ្យ ។

-ជូនសមុខប្រធានគណៈបញ្ជាការ ដើម្បីធ្វើការប្រជុំត្រួតពិនិត្យជាសៃាមញ្ញជាមួយគណៈបញ្ជាការឯកភាពរាជធានី-ខេត្ត និងអង្គភាពពាក់ព័ន្ធជុំវិញការលុបបំបាត់ការដាក់ប៉ុស្តិ៍អនាធិបតេយ្យតាមផ្លូវគោក និងផ្លូវទឹក ។

-ធ្វើរបាយការណ៍អំពីសភាពការណ៍ និងលទ្ធផលជូនគណៈបញ្ជាការ រៀបចំការប្រជុំ និងកិច្ចការរដ្ឋបាលផ្សេងៗបំរើដល់គណៈបញ្ជាការ ។

**ប្រការ៥ ៖** ប្រធានគណៈបញ្ជាការឯកភាពរាជធានី-ខេត្ត គឺជាប្រធានគណៈបញ្ជាការដឹកនាំត្រួតពិនិត្យ និងលុបបំបាត់ការដាក់ប៉ុស្តិ៍ត្រួតពិនិត្យអនាធិបតេយ្យតាមផ្លូវគោក និងផ្លូវទឹក ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។

**ប្រការ៦ ៖** គណៈបញ្ជាការ និងលេខាធិការដ្ឋាន ដឹកនាំត្រួតពិនិត្យ និងលុបបំបាត់ការដាក់ប៉ុស្តិ៍ត្រួតពិនិត្យអនាធិបតេយ្យតាមផ្លូវគោក និងផ្លូវទឹក មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងមហាផ្ទៃ ក្នុងកិច្ចដំណើរការកិច្ចការរដ្ឋបាលរបស់ខ្លួន ។

**ប្រការ៧ ៖** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ អគ្គស្នងការ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ មេបញ្ជាការកងទ័ពជើងគោក មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស មេបញ្ជាការ កងទ័ពជើងទឹក គណៈបញ្ជាការឯកភាពរាជធានី-ខេត្ត ក្រសួងស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ដែលមានចែងក្នុង ប្រការ១ ប្រការ៣ និងប្រការ៦ ត្រូវអនុវត្តសេចក្តីសម្រេចនេះចាប់ពីថ្ងៃ ចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ... ខែ ... ឆ្នាំ២០១២

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល ៖</u>

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចប្រការ៧
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ